អត្ថាធិប្បាយលេខនេះ

# ការសម្តែងមតិចំពោះរដ្ឋាភិបាលប្រជាធិបតេយ្យ

រដ្ឋាភិបាលដែលគ្រប់គ្រងអំណាចនៅគ្រប់ប្រទេសលើពិភពលោក ទោះបីជាប្រកាន់របបនយោបាយខុសគ្នាយ៉ាងណាក៏ដោយ គេតែងចង់បានការកោតសរសើរ ជាជាងការរិះគន់នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់ខ្លួន ព្រោះគេយល់ឃើញថាការដឹកនាំរបស់គេល្អ ស្របទៅតាមគោលនយោបាយរបស់ប្រទេសជាតិ និងឆន្ទៈរបស់ប្រជាពលរដ្ឋ។

ថ្វីត្បិតតែមាននិន្នាការស្របគ្នាក៏ដោយ តែការប្រកាន់របបនយោបាយគឺខុសគ្នា យើងអាចសង្កេតឃើញ ការដឹកនាំប្រទេសអាចមានការប្រែប្រួលទៅតាមស្ថានការណ៍ប្លែកៗពីគ្នាដោយការប្រកាន់របបនយោបាយខុសៗគ្នានោះ។

ពោលគឺរបបរាជានិយមខុសគ្នាអំពីរបបសាធារណរដ្ឋនិយមហើយរបបទាំងពីរនេះ និងរបបសង្គមនិយមវាខុសប្លែកគ្នាពីរបបប្រជាធិបតេយ្យ។

ដោយឡែកប្រទេសដែលប្រកាន់យករបបនយោបាយប្រជាធិបតេយ្យ មានលក្ខណៈពិសេសត្រង់ចំណុចមួយគឺប្រជាធិបតេយ្យបានផ្តល់នូវការសម្តែងមតិពីប្រជារាស្ត្រក្នុងការទិតៀនស្លាបនាលើបញ្ហាសំខាន់ៗ ដែលកើតមាននៅក្នុងសង្គម។

ការសម្តែងមតិក្នុងសង្គមប្រជាធិបតេយ្យមានន័យថា មនុស្សមានសេរីភាព និយាយស្តីតែងតែជជែកដេញដោល ការប្រមូលផ្តុំជួបជុំធ្វើការបោះឆ្នោតគាំទ្របុជំទាស់ដើម្បីធានាបាននូវយុត្តិធម៌ សម្រាប់ជនគ្រប់រូប ហេតុដូចនេះហើយទើប ការសម្តែងមតិក្នុងសង្គមប្រជាធិបតេយ្យ ត្រូវបានគេចាត់ទុកថាជាសរសៃឈាមជីវិតនៃលទ្ធិប្រជាធិបតេយ្យ។

ដូច្នេះ លំហូរចូលដោយគ្មានកម្រិតនៃមតិ និងដំណឹងដែលគេហៅ ថាសេរីភាពសារព័ត៌មាន ក្នុងការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក អំពីបញ្ហារួមរបស់គេ គឺការសម្រេចចិត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រង ត្រូវមានសេរីភាពខាងការសម្តែងមតិជាមុនសិន។

ត្រង់ចំណុចនេះ ចំពោះអ្នកនិយមអំណាចផ្តាច់ការ និងអ្នកនិយមរិះគន់លទ្ធិប្រជាធិបតេយ្យ គេយល់ច្រឡំថាប្រជាធិបតេយ្យខ្វះអំណាចក្បៀបសង្កាត់ផង និងអំណាចដឹកនាំផង។

ជាមូលដ្ឋាន ទស្សនៈបែបនេះពិតជាយល់ខុសធំហើយ ព្រោះប្រជាធិបតេយ្យ ទាមទារឲ្យកម្រិតអំណាចរបស់រដ្ឋាភិបាល មិនមែនទាមទារឲ្យរដ្ឋាភិបាលទន់ខ្សោយនោះឡើយ។

ទិដ្ឋភាពនៃប្រជាធិបតេយ្យ ដែលធ្វើឲ្យប្រជាធិបតេយ្យរស់រវើកនោះគឺការជជែកដេញដោល ខ្វែងគំនិតគ្នា និងការសម្រុះសម្រួលគំនិតគ្នា ដែលអ្នកខ្លះរិះគន់ថាជាចំណុចខ្សោយនោះ តាមការពិតគឺជា ***កម្លាំងមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ***។

ចំណែករដ្ឋាភិបាលប្រជាធិបតេយ្យដែលឈរលើការព្រមព្រៀង ពេញចិត្ត ឯកភាព ពីជនដែលខ្លួនគ្រប់គ្រង អាចនិយាយ និងធ្វើសកម្មភាពពោរពេញ ដោយសេចក្តីទុកចិត្តខ្លួនឯងព្រមនឹងមានអំណាចដែលបានមកពីការបោះឆ្នោត សម្តែងការទុកចិត្ត។ ប៉ុន្តែប្រសិនបើការបោះឆ្នោតនោះ ពុំមានភាពសេរីយុត្តិធម៌ និងប្រកបដោយភាពលម្អៀងទេនោះ ឬជារដ្ឋាភិបាលដែលបានបន្តបឡើងដោយអំណាចផ្តាច់ការនៃកម្លាំងយោធានោះនឹងមិនអាចធ្វើបានដូចបញ្ជាក់ខាងលើនេះទេ។

ការលើកហេតុផលបែបនេះ គឺសំដៅទៅលើអំណាចរដ្ឋាភិបាលប្រជាធិបតេយ្យ ដែលចាំបាច់សេចក្តីសម្រេចបែបប្រជាធិបតេយ្យត្រូវធ្វើឡើងសមស្របតាមផលប្រយោជន៍មួយដែលទាំងអស់គ្នាអាចទទួលយកបាន ព្រោះរដ្ឋាភិបាលប្រជាធិបតេយ្យត្រូវបានបង្កើតឡើងដោយសារសន្លឹកឆ្នោត រដ្ឋាភិបាលនោះត្រូវតែទទួលបាននូវការសម្តែងមតិពីរាស្ត្រ ឬសម្តែងឆន្ទៈ និងយោបល់ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

ដូចនេះនៅក្នុងទស្សនៈនៃរដ្ឋាភិបាលដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យមួយចំនួន ទោះបីជាចង់បាននូវការសាទរសរសើរក៏ដោយ ក៏បែបផែនប្រជាធិបតេយ្យពិតៗ ត្រូវបានសម្តែងចេញឡើងនូវភាពស្មោះត្រង់ ទទួលស្គាល់នូវអ្វីដែលជាកំហុស។ គេត្រូវតែហ៊ានទទួលខុសត្រូវនូវអ្វីដែលគេបាន ឬធ្វើមិនបាន ត្រូវហ៊ានចុះចេញពីតំណែង ចំពោះអំពើពុករលួយអ្វីមួយរបស់គេ ដូចជាការងារអសកម្មផ្ទាល់របស់គេ ឬដោយសារការដោះស្រាយពុំបាននូវបញ្ហាចំពោះមុខ។

ដោយឡែក នៅក្នុងស្ថានភាពបច្ចុប្បន្ន សម្រាប់ប្រទេសកម្ពុជាយើង ដែលត្រូវបានគេចាត់ទុកថាជាប្រជាធិបតេយ្យនូវក្មេងខ្ចី នៅមានបញ្ហាប្រឈមជាច្រើននៅឡើយ រួមទាំងបណ្តាប្រទេសនៅតំបន់អាស៊ីមួយចំនួនផងដែរ។

បច្ចុប្បន្ន រដ្ឋាភិបាលមួយចំនួន នៅតំបន់អាស៊ី បានអនុវត្តនូវរបបប្រជាធិបតេយ្យល្អប្រសើរ តែខ្លះទៀតនៅពុំទាន់បានឈានទៅរកអ្វីដែលជាប្រជាធិបតេយ្យពិតប្រាកដនៅឡើយ

ទេ ដោយភាគច្រើនរដ្ឋាភិបាលដែលគ្រប់គ្រងអំណាច នៅពុំទាន់សម្របសម្រួលខ្លួនទៅនឹងពាក្យរិះគន់ ទិតៀន ស្តាបនាបាននៅឡើយ។

មិនតែប៉ុណ្ណោះអ្នកកាន់អំណាចគេបានចាត់ទុកថា ការទិតៀន ឬរិះគន់ គឺជាការជំទាស់ ហើយមានទស្សនៈថា មានតែជនមួយក្តាប់តូចប៉ុណ្ណោះ ដែលច្រើនតែជំទាស់នឹងទង្វើរបស់រដ្ឋាភិបាល...។ អ្វីដែលធ្ងន់ជាងនេះនោះ គឺរដ្ឋាភិបាលច្រើនតែភ្ជាប់អ្នកមានមតិទាំងនោះថា ជាបក្សពួកតែមួយនៃអ្នកប្រឆាំង ឬគណបក្សប្រឆាំងរួមគ្នាតែម្តង។

ប៉ុន្តែ រដ្ឋាភិបាលគ្រប់គ្រងអំណាចណា ដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ហើយពុំអាចទទួលយកបាននូវការរិះគន់ ទិតៀន ស្តាបនា រដ្ឋាភិបាលនោះ ពុំមែនជាអ្នកប្រជាធិបតេយ្យពិតប្រាកដឡើយ គឺជាប្រជាធិបតេយ្យដែលពោលតែមាត់ ឯសកម្មភាពធ្វើផ្សេង ហើយយកស្លាកប្រជាធិបតេយ្យមកបិទបាំង។

ជាការពិតនោះ ក្នុងសង្គមប្រជាធិបតេយ្យមិនមែនមានតែចំណុចនៃការសម្តែងមតិនោះទេ គឺនៅមានចំណុចច្រើនទៀត ដូចជាការបោះឆ្នោតប្រកបដោយសេរីយុត្តិធម៌ អង្គការក្រៅរដ្ឋាភិបាល(សង្គមស៊ីវិល) ដែលជាអ្នកចូលរួមក្នុងការអភិវឌ្ឍន៍ និងជួយបំពេញនូវចំណុចខ្វះខាតរបស់រដ្ឋាភិបាល តាមរយៈសេរីភាពបញ្ចេញមតិសារព័ត៌មាន មតិគណបក្សប្រឆាំងនឹងការគោរពសិទ្ធិជាមូលដ្ឋានរបស់មនុស្ស។ល។ ដែលផលសម្រេចនៃសិទ្ធិទាំងនេះ ស្តែងឡើងតាមរយៈអ្វីក៏ដោយ ត្រូវតែទទួលបាននូវការគោរព និងបើកទូលាយឲ្យបានស្មើគ្នា។

ដោយហេតុថា មនុស្សម្នាក់ៗ មិនអាចរស់នៅដោយទទួលបានសិទ្ធិមួយពេញលេញ ហើយសិទ្ធិដទៃទៀតត្រូវបានបិទជិតឃឹងនោះឡើយ។ឧទាហរណ៍នៅក្នុងកិច្ចប្រជុំមួយប្រសិនបើមានមតិភាគច្រើនសម្រេចចិត្ត ទទួលយកចំណុចអ្វីមួយតែនៅក្នុងនោះក៏មានមតិជំទាស់ដែរ គឺអង្គប្រជុំនោះត្រូវតែទទួលយក មតិជំទាស់ភាគតិចនោះដើម្បីពិនិត្យពិចារណា ព្រោះមតិជំទាស់ភាគតិចមិនមែនសុទ្ធតែអាក្រក់ ហើយមតិយល់ស្របភាគច្រើនមិនមែនសុទ្ធតែល្អនោះទេ។

ក្នុងន័យនេះប្រៀបដូចជា ការបង្កើតរដ្ឋាភិបាលក្នុងអាណត្តិនីមួយៗដូច្នេះដែរ គឺត្រូវមានរដ្ឋាភិបាលចម្រុះនៅក្នុងសភា ហើយនៅក្នុងនោះ ក៏ត្រូវតែមានសំឡេងរបស់គណបក្សប្រឆាំងផងដែរ។

ទាក់ទិនទៅនឹងសេរីភាពសារព័ត៌មាន នៅក្នុងហេតុការណ៍ថ្មីៗនេះ សារព័ត៌មានបានរាយការណ៍អំពីការដាប់ថ្ម អង្គរ ដាក់ភ្លើងបំភ្លឺ ដូច្នេះរដ្ឋាភិបាលត្រូវតែទៅផ្ទៀងផ្ទាត់ព័ត៌មាននោះ ហើយស្រាយបំភ្លឺតាមរយៈសារព័ត៌មាន ដើម្បីឲ្យមហាជនអស់ចម្ងល់នេះ ថាតើមានដាប់ថ្ម ដែលជាបេតិកភ័ណ្ឌជាតិនេះដែរឬទេ?

ចំពោះបញ្ហាពាក់ព័ន្ធ និងអភិវឌ្ឍវិញអង្គការដែលធ្វើការងារអភិវឌ្ឍន៍នៅពេលដែល ឃើញមានចំណុចខ្វះខាតរបស់រដ្ឋាភិបាល គេបានស្នើសុំឲ្យរដ្ឋាភិបាលពិចារណាឡើងវិញលើគម្រោងណាមួយនោះ រដ្ឋាភិបាលក៏ត្រូវតែធ្វើការពិចារណាឡើងវិញដែរ។

ប្រសិនបើមានការរំលោភសិទ្ធិមនុស្ស នៅក្នុងការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅស្ថាន ដើម្បីយកទីតាំងធ្វើការអភិវឌ្ឍន៍អង្គការផ្នែកសិទ្ធិមនុស្សក៏បានអំពាវនាវទៅរដ្ឋាភិបាល លើការបណ្តេញចេញនេះ ដោយឲ្យមានការសងជាសំណងសមរម្យ និងដោះស្រាយទៅតាមផ្លូវច្បាប់ ដែលនេះ គឺជាការបំពេញនូវកង្វះខាត។

ព័ត៌មានទាំងនេះ គឺរដ្ឋាភិបាលជា អ្នកសម្រេចព្រោះជាកិច្ចការដែលខ្លួនជាអ្នកអនុវត្ត និងត្រូវដោះស្រាយបញ្ហាដោយបំភ្លឺជូនឲ្យអស់នូវក្តីបារម្ភ ឬបញ្ហានោះត្រូវដោះស្រាយបែបណា? ហើយនេះ គឺជាវិធីសាស្ត្រល្អបំផុតដែលជួយឲ្យរដ្ឋាភិបាលដែលកាន់អំណាចប្រព្រឹត្តទៅតាមគន្លងច្បាប់ លើកស្ទួយសិទ្ធិមនុស្ស និងការការពារលទ្ធិប្រជាធិបតេយ្យផងដែរ។

ដោយឡែក អង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាល ដែលបានផ្តល់មតិទិតៀនស្តាបនា មិនបានសំដៅទៅដណ្តើមអំណាច ឬជួយដល់គណបក្សនយោបាយ ណាមួយឡើយ (លើកលែងតែអង្គការនោះលម្អៀងទៅបម្រើគណបក្សនយោបាយ ឬចង់ធ្វើនយោបាយ) ព្រោះបើជាអង្គការ ដែលមានគោលការណ៍ឯករាជ្យ មិនប្រកាន់គណបក្សនយោបាយ មិនលម្អៀង គឺជាការជួយផ្តល់មតិ ជួយបំពេញកង្វះខាតរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។

ចំណុចដែលលើកជាឧទាហរណ៍នេះ គឺដើម្បីបង្រួបន័យសេចក្តីខាងលើអំពីការកម្រិតអំណាចរដ្ឋាភិបាលនៅក្នុងលទ្ធិប្រជាធិបតេយ្យដែលធ្វើឲ្យប្រជាធិបតេយ្យរស់រវើក ហើយអាចនឹងស្តាបនាប្រទេសឲ្យទៅជានីតិរដ្ឋ ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ៕

**អ្នកជា**